ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ០៥៣ សសរ.

# សេចក្តីសម្រេច

# ស្តីពី

# ការកែសម្រួលសមាសភាពគណៈកម្មការចំណាត់ថ្នាក់ ពិនិត្យវាយតម្លៃ ដំឡើងឋានន្តរស័ក្តិ ឬដំឡើងថ្នាក់ ឬផ្តល់មេដាយការងារជូនមន្ត្រីរាជការ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ ២០១៤ ស្តីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ ២០១៦ ស្តីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងសេចក្តីសម្រេចលេខ ០៥៣ ដនស.សសរ ចុះថ្ងៃទី ១២ ខែកក្កដា ឆ្នាំ ២០១៦ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មការចំណាត់ថ្នាក់ ពិនិត្យវាយតម្លៃ ដំឡើងឋានន្តរស័ក្តិ ឬដំឡើងថ្នាក់ ឬផ្តល់មេដាយការងារជូនមន្ត្រីរាជការ
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**ប្រការ ១._**

កែសម្រួលសមាសភាពគណៈកម្មការចំណាត់ថ្នាក់ ពិនិត្យវាយតម្លៃដំឡើងឋានន្តរស័ក្តិ ឬដំឡើងថ្នាក់ ឬផ្តល់មេដាយការងារជូនមន្ត្រីរាជការ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ឆាន់ សាផាន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. | ឯកឧត្តម **ខិម សំអ៊ែល** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

| | | |
|---|---|---|
| ៣. ឯកឧត្តម **សេង ឡូត** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល | អនុប្រធាន |
| ៤. លោក **កុសល សុពិនត្ស** | ប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៥. លោក **ញ៉ៀប ផន** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិកអចិន្ត្រៃយ៍ |
| ៦. លោក **ច្រាក់ សុខសត្យា** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៧. លោក **លីវ ពិសិដ្ឋ** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៨. លោក **គឹម ប៊ុនថន** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ៩. លោក **មាស ដារ៉ា** | អនុប្រធាននាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០. លោក **ឃុន ចាន់ធន** | ប្រធានការិយាល័យបុគ្គលិក | សមាជិក |
| ១១. លោកស្រី **លុន ពុធារី** | ប្រធានការិយាល័យក្របខ័ណ្ឌនិងបៀវត្ស | សមាជិកា |
| ១២. ប្រធាន ឬតំណាងអង្គភាព | | សមាជិក |
| ១៣. អ្នករាជការមួយរូបដែលមានក្របខ័ណ្ឌជាមួយគ្នា | | សមាជិក |

**ប្រការ ២.**_

គណៈកម្មការនេះមានភារកិច្ចពិនិត្យវាយតម្លៃ ដើម្បីដំឡើងឋានន្តរស័ក្តិ ឬដំឡើងថ្នាក់ ឬផ្តល់មេដាយការងារ ជូនមន្ត្រីរាជការសកម្ម ជាពិសេសមន្ត្រីរាជការដែលជិតចូលនិវត្តន៍ ជូនថ្នាក់ដឹកនាំក្រសួងសម្រេចតាមគោលការណ៍។

**ប្រការ ៣.**_

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ ៤.**_

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយក អគ្គាធិការ គ្រប់ប្រធាននាយកដ្ឋាន អង្គភាពពាក់ព័ន្ធ និងសាមីខ្លួនដូចមានរាយនាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ១២ រោច ខែ ស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៨

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

ជា សុផារ៉ា

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៤
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ